F08

M11

ML MLUP BAITONG

# បរិស្ថានខ្ញុំ

ចេញផ្សាយប្រចាំ ៣ខែ ម្តង (លេខ២)    ឆ្នាំទី១ ខែកក្កដា_កញ្ញា ឆ្នាំ២០០១

# តួនាទីរបស់ព្រៃឈើ



ឈ្មោះ មៀច វណ្ណៈ ថ្នាក់ទី៥ បឋមសិក្សាបន្ទាប់



ឈ្មោះ សឿង ណាប់ ថ្នាក់ទី៥ បឋមសិក្សាគិរីវិណ្ណ



ឈ្មោះ តូច សុខទី ថ្នាក់ទី៥ បឋមសិក្សាមហាសាំង



ឈ្មោះ ហេង ចន្ធូ ថ្នាក់ទី៥ សាលាបឋមសិក្សា[illegible]



ឈ្មោះ ប៊ុត ប៊ុយ សាលាបឋមសិក្សាគិរីវិណ្ណ



ឈ្មោះ [illegible]



ឈ្មោះ [illegible] សាលាបឋមសិក្សាមហាសាំង

ហាមលក់

# សួស្តី !



យ៉ាង សេងគិច     ថ្នាក់ទី៥ សាលាមហាសាំង

ប្អូនៗ សិស្សានុសិស្សទាំងអស់គ្នា ពេលនេះ ព្រឹត្តិបត្រ " **បរិស្ថានខ្ញុំ** " លេខ ពីរ ឆ្នាំទីមួយ បានមកជួប នឹងប្អូនទៀតហើយ ។

តើប្អូនៗសុខសប្បាយ រឺទេ?

ព្រឹត្តិបត្រ " **បរិស្ថានខ្ញុំ** " មានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានមកជួបប្អូនៗតាមពាក្យសន្យា បី ខែម្តង ។

ដោយសារការចូលរួម សរសេរជា សំនួរ អត្ថបទ និងគូររូបភាពរបស់ប្អូនៗ យ៉ាងល្អបំផុតនេះហើយ ទើបព្រឹត្តិបត្រ ដែលប្អូនៗកំពុងកាន់នេះ ត្រូវបានបន្ថែម **បួន** ទំព័រទៀត ។យើងជឿជាក់ថាប្អូនៗ នឹងសប្បាយរីករាយ ក្នុងការអាន ។

**តែកុំភ្លេចណា** ! លេខក្រោយយើងនឹងចេញផ្សាយអំពី " **សត្វព្រៃ** " ដូច្នេះប្អូនត្រូវ បន្តផ្ញើ តាមប្រអប់សំបុត្រ អោយបានច្រើនថែមទៀត ។

បរិស្ថានខ្ញុំ ស្ថានខ្ញុំ !




## មាតិការឿង


១ តួនាទីរបស់ព្រៃឈើ

២ ស្វែងយល់

៣ នាទីកំសាន្ត

៤ ស្នាដៃគ្រូ និង សិស្ស

៥ ភូមិភាគឥសាន្ត

៦ សំណួរចំលើយ

៧ ល្បងប្រាជ្ញា



# តួនាទីរបស់ព្រៃឈើ

ថ្ងៃនេះ " **បរិស្ថានខ្ញុំ** " សូមនាំប្អូនៗអោយទៅមើលដើមឈើមួយដើម។ ហើយជួយគ្នារកថាតើ **ឈើមានប្រយោជន៍ អ្វីខ្លះ ?**

**មែនហើយ!** ឈើដែលដុះច្រើន ហើយធំល្វឹងល្វើយនោះ គឺវាអាចស្រូបយក ពន្លឺព្រះអាទិត្យ ទឹក ឧស្ម័នផ្សេងៗ បញ្ចេញទៅក្នុងបរិយាកាស ដែលមនុស្ស សត្វ រុក្ខជាតិត្រូវការ។ ម្យ៉ាងទៀត ឈើបានផ្តល់ស្លឹក គ្រាប់ ផ្លែ ហើយក៏ជួយឱ្យមានខ្យល់ត្រជាក់ និងបរិសុទ្ធទៀតផង។



( ដំណើរទស្សនៈកិច្ចសិក្សាសាលាបឋមសិក្សា ៧មករា នៅឧទ្យានជាតិ គិរីរម្យ )

ប្អូនត្រូវដឹងទៀតថា ព្រៃឈើជួយទាក់ទាញទឹកភ្លៀង ការពារដី ការពារការហូរច្រោះ មិនធ្វើអោយមានទឹកជំនន់ ជារទាំងខ្យល់ព្យុះ រួមទាំងជាសំរស់ធម្មជាតិ ដ៏ល្អត្រកាលទៀតផង។

ដូចនេះ ប្អូនៗត្រូវតែស្វែងយល់អំពី ផលប្រយោជន៍ដើមឈើអោយបានច្រើន និងរួមគ្នាជួយការពារ ថែរក្សាព្រៃឈើអោយបានគង់វង្ស រហូតទៅ។



# ស្វែងយល់

ចូរគូសសញ្ញា ( ✓ ) នៅក្នុងប្រអប់ចំលើយដែលត្រឹមត្រូវ ☑



| | |
|---|---|
| - គ្រោះរាំងស្ងួត ☐ | - អាកាសធាតុប្រែប្រួល ☐ |
| - ភ្លៀងមិនទៀងទាត់ ☐ | - ដីមានជីជាតិ ☐ |
| - សំបូរជំរកសត្វ ☐ | - បរិស្ថានគ្មានលំនឹង ☐ |



**មានព្រៃឈើនាំមកនូវ**

| | |
|---|---|
| - ខ្យក់ទឹកភ្លៀង ☐ | - គ្មានគ្រោះទឹកជំនន់ ☐ |
| - គ្មានខ្យល់ព្យុះ ☐ | - មិនសំបូរសត្វព្រៃ ☐ |
| - ទាក់ទាញទឹកភ្លៀង ☐ | - អាកាសធាតុក្តៅ ☐ |



# នាទីកំសាន្ត

ក្មុយ មានក្លើម្នាក់ឈ្មោះ ក្លយ នៅឯជនបទ ។ ថ្ងៃមួយបានជួបសំណេះសំណាលគ្នាថា៖

ក្មុយ- តើសំលាញ់ឯងប្រកបមុខរបរអ្វី? សព្វថ្ងៃនេះ!

ក្លយ- សព្វថ្ងៃគ្នារកស៊ីចូលព្រៃកាប់ឈើ...

ក្មុយ- បើឯងកាប់ព្រៃឈើច្រើនរាល់ថ្ងៃ ព្រៃឈើនឹងហិនហោច ហើយវ៉ើយ!




ក្លយ- យីសំលាញ់ហិនហោចអី? កាប់ច្រើនដុះកាន់តែច្រើនវ៉ើយ!

ក្មុយ- ដុះស្អីវ៉ើយ!

ក្លយ- ដុះដើមកន្ទ្រៀងខែត ហ្នឹងណា!



ក្មុយ- អុញ ???

**“ បំផ្លាញព្រៃឈើនាំអោយជួបប្រទះនូវគ្រោះធម្មជាតិ”**

# ល្បៃប្រាជ្ញ សិស្ស



## វាចាព្រៃឈើ

កំណាព្យ ( បទភាកគតិ )



ឈ្មោះ ហង្ស ពាន់ ថ្នាក់ទី៥ក សាលាបឋមសិក្សា

របខ្ញុំជាឈើ រាល់ថ្ងៃខំធ្វើ កិច្ចការឥតណាយ
អោយខ្លួនបានធំ ត្រសុំត្រសាយ ពង្រឹងរូបកាយ
បំរើសត្វលោក ។

ឈើខ្ញុំនេះណា បំរើមនុស្សសា បានគ្រប់ជំពូក
ខ្ញុំគោងការពារ មនុស្សម្នារហូត ឱ្យចាកផុតទោស
ពីគ្រោះធម្មជាតិ ។

ដូចជាខ្ញុំឈរ បាំងនិងពន្លឺ ផ្តល់ជាជំរក
ការពារកំដៅ បាំងទៅមនុស្សលោក ត្រជាក់រហូត
ដូចទឹកអម្រិត ។

មិនតែប៉ុណ្ណោះ ខ្ញុំជួយទាំងអស់ ចំពោះជីវិត
មនុស្សសត្វទាំងពួង មិនអោយភ័យភិត ពីជនឧក្រិត
គឺព្យុះកំណាច ។



ខាងខ្ញុំ

សាលាបឋម



ម្យ៉ាងទៀតខ្លួនខ្ញុំ តែងតែខិតខំ សន្សំបីតស្រូប
យកនូវជាតិទឹក ដែលធ្លាក់ភ្លៀងមក បន្ថយបាតុភូត
គ្រោះទឹកជំនន់ ។

 ឈ្មោះ តែ ភា សាលាបឋមសិក្សាបន្ទាប់

ដោយសាឫសខ្ញុំ ទី. ួយភាគធំ ត្រូវបានដំកល់
ក្នុងឈើមួយដើម ស្តុកបានទៅដល់ ត្រិតក្រំដំរូវ
ដល់ទៅពាន់លីត្រ ។





ឈ្មោះ ស៊ុម រ៉ូ ថ្នាក់ទី៥

ដូច្នេះបើខ្ញុំ មានគ្នានៅភ្នំ ព្រមទាំងទំនាប
រៀបរាប់ចំនួន មានច្រើនលានកោដិ ខ្ញុំបឺតទឹកយក
បានប៉ុន្មានទៅ ។

ទឹកខ្ញុំបឺតបាន ហួសពីការស្មាន កំណត់មិនត្រូវ
បើសិនទឹកជន់ ខ្ញុំនឹងតំរូវ អោយទឹកចុះទៅ
សំរកវិញបាន ។



ឈ្មោះ យុន ចាន់សូ
វិទ្យាមហាសាំងថ្នាក់ទី ៥ "ក"

ពាក្យដែលខ្ញុំថា រៀបរាប់វាថា ទាំងអំបាលម៉ាន
អាចជារនាំង ការពារមនុស្សបាន ឱ្យសុខក្សេមក្សាន្ត
បានរៀងរហូត ។

ព្រោះអត់រូបខ្ញុំ សត្រូវធំៗ ចូលមកប្រហា
គ្រោះទឹកជំនន់ សាហាវឫស្សា បំផ្លាញជីវា
គ្មានត្រាប្រណី ។

មិនតែប៉ុណ្ណោះ ព្យុះនឹងបោកបក់ ឱ្យអ្នកក្សិនក្សយ
កំទេចទាំងអស់ មិនអោយសល់អ្វី រស់វេទនាក្រៃ
ចៀសក្សយមិនផុត ។

(និពន្ធដោយ ក្រុមក្លឹប មនសិការកុមារព្រែកត្រយឹង រៀននៅថ្នាក់ទី ៥
នៃសាលាបឋមសិក្សាព្រែកត្រយឹង កែសំរួលដោយ លោកគ្រូ រស់ ឡុង )



# ភូមិភាគឦសាន្ត

១- ភូមិភាគឥសាន្ត អាណាខេត្តខ្មែរ ដូនតាបានថែ ទុកជាមរតក

សម្បត្តិធម្មជាតិ សំបូឥតខ្ចោះ ទឹកឡើងស្រណោះ ឧទ្យានវិរៈជ័យ ។

២- ព្រឹកព្រៃសែនធំ ភ្នំវែងអន្លាយ ទេសភាពជិតឆ្ងាយ ជាទីគយគន់

បក្សា បក្សី ហោះហើរស្រែកច្រៀង ពួសួរចំរៀង អូនច្រៀងបំពេរបង ។

៣- នៅលើខ្នងភ្នំ ទោចយំគ្រលួច ដូងចិត្តព្រឺព្រួច ទឹកដល់រូបស្រិ

អស់ឱវិរៈជ័យ ខ្ញុំសូមសច្ចា ជួយថែរក្សា អ្នកមិនអោយហ្មង ។

៤- ឧទ្យានវិរៈជ័យ ប្រពៃសោភា យើងធ្លាប់សន្ទនា ស្នេហ៍ស្មោះភក្តិ

មានអូរខាំផា ជាកសិណសាក្សី ចាំខ្ញុំស្នេហ៍ស្រិ លុះក្ស័យសង្ខា ។

៥- ទឹកអើយសែនទឹក ទឹកគ្រប់អនុស្សា ទីធ្លាប់សច្ចា នៅជ្រោយសាយសុង

ស្តាប់សូរទឹកធ្លាក់ ដូចភ្លេងប្រគំ កំដរស្នេហ៍មុំ ហើយនិងមាសបង ។



## សំពត់ វំលើយសិស្សតាមរយៈប្រអប់សំបុត្របរិស្ថានខ្ញុំ

តើយើងអាចហៅ
ដើមឈើជាព្រៃ
ឈើបានទេ?

ពិន ដារិទ្ធ សិស្សថ្នាក់ទី ៦ក
សាលាបឋមសិក្សាត្រែងត្រយឹង

គេមិនអាចហៅដើមឈើមួយដើមថាជាព្រៃឈើបានទេ លុះត្រាតែដើមឈើទាំងនោះដុះតៗគ្នា ដុះបញ្ជៀតគ្នាបានច្រើន ទើបគេអាចហៅថាព្រៃឈើបាន។ ដូច្នេះព្រៃឈើគឺជាព្រៃដែលដុះច្រើនកកកុញ ហើយមានរុក្ខជាតិ និង ឈើច្រើនយ៉ាង សត្វល្អិត និងសត្វព្រៃផ្សេងៗទៀតនៅលាយឡំគ្នាជាលក្ខណៈធម្មជាតិ។

ហេតុអ្វីបានជាព្រៃឈើ
កាន់តែហោចទៅៗ?

នាងខ្ញុំឈ្មោះ ឃុន សុធារី
សាលាបឋមសិក្សាមហាសាំង

បានជាព្រៃឈើកាន់តែហោចទៅៗ គឺដោយសារតែយើងទាំងអស់គ្នាមិនយល់ពីប្រយោជន៍នៃព្រៃឈើ មនុស្សមិនសូវមានចំណេះដឹង ចេះតែកាប់បំផ្លាញព្រៃឈើដោយមិនសមហេតុផល ប្រើវិធីសាស្ត្រគ្រប់បែបយ៉ាងដើម្បីបំផ្លាញទាំងឈើគ្រប់អាយុកាប់ និង មិនគ្រប់អាយុ ។

បើយើងមិនដាំឈើបានតើ
មានផលប្រយោជន៍ទេ?
តើខ្ញុំគួរតែដាំព្រៃឈើ
ដើម្បីអោយស្អាតភូមិឋាន

សួង ធារី ភេទស្រី
សាលាបឋមសិក្សាឋបកា

បើប្អូនខាដាំព្រៃឈើបាន នោះគឺមានប្រយោជន៍ណាស់សំរាប់ភូមិស្ថាននិងប្រទេសរបស់ប្អូន ក៏ដូចជាសកលលោកទាំងមូលដែរ វាមិនមែនធ្វើអោយរខេ័សភូមិឋាននោះទេ តែផ្ទុយទៅវិញ វានាំអោយផ្ទះសំបែង ឬភូមិឋានបានស្អាត ឈើអាចដាំលំអផ្ទះជាមួយ ផ្តល់ផ្លែហូប ឬអាចបេះ បានទៀតផង។

ហេតុអ្វីបានជានៅស្រុកយើងមានភ្លៀងមិនទៀងទាត់យ៉ាងនេះ?

គិន វុឌ្ឍី ថ្នាក់ទី ៦ខ
សាលាបឋមសិក្សាគីរីវ៉ល្លិ

មិនថាតែស្រុកយើងទេ ដែលមានភ្លៀងមិនទៀងទាត់ ប្រទេសណាក៏ដោយ អោយតែកាប់បំផ្លាញព្រៃឈើ នោះនាំអោយមានអាកាសធាតុប្រែប្រួល ភ្លៀងធ្លាក់មិនទៀង មានគ្រោះទឹកជំនន់។ ដូច្នេះទោះជាប្រទេសគេមានព្រៃឈើ តែយើងគ្មានក៏ធ្វើអោយ មានភ្លៀងមិនទៀងទាត់ដែរ ព្រោះវាមានទំនាក់ទំនងជាមួយគ្នា ហើយព្រៃឈើគឺជាអ្នក ទាក់ទាញទឹកភ្លៀង។

បើយើងអាចរក្សាព្រៃឈើបាន តើអាកាសធាតុល្អ ឬអាក្រក់?

ឃុន វ៉ាន់ចាន់តុលា ថ្នាក់ទី ៥ខ
សាលាបឋមសិក្សាត្រពាំងអោប

បើយើងអាចរក្សាព្រៃឈើបាន នោះអាកាសធាតុគឺពិតជាល្អតែបើនៅតែ មានអាកាសធាតុ ប្រែប្រួលទៀត ទាល់តែគ្រប់ប្រទេសទាំងអស់សំបូរព្រៃឈើដូចគ្នា នឹងជួយថែរក្សាព្រៃទាំងនោះទាំងអស់គ្នា ។

---

អបអរសាទរ ចំពោះប្អូន **កាន់ ចាន** រៀននៅសាលាបឋមសិក្សាគីរីវ៉ល្លិ ដែលបានគូររូបភាព ស្តីអំពីទំនាក់ទំនងដើមឈើជាមួយសត្វព្រៃ ។



**សូមប្អូនៗ សរសេរសំបុត្រ ឬគូររូបភាពស្តីពី "សត្វព្រៃ" ដាក់ក្នុងប្រអប់សំបុត្រ ដើម្បីចុះផ្សាយលេខក្រោយទៀត**



# ល្បែងប្រាជ្ញា



អស់នឹងគេ ងើបនឹងពោះ

ចំណែកនាងនោះងើបនឹងកគឺអ្វី ?

---



រុក្ខារក្សាស្រុក អង្គុយសំកុក

មិននិយាយស្តី- នោះជាអ្វី ?

---



រុក្ខាមានឈ្មោះបីម៉ាត់ ឈុបខាងចុងបាត់

ឈ្មោះជាផ្លែទីពា- តើជាអ្វី ?

# អឺយ៉ា!

លោកអ្នកស្គាល់សញ្ញា [illegible]

ប្រចាំតំបន់ការពារ?

ប្រលងប្រណាំងផ្គូផ្គងរក [illegible]!

Mlup Baitong PO Box 2510 Phnom Penh 3 Cambodia
Tel Fax ++855-23-214-409 Mobile ++855 11 812-208 e mail mlup@forum.org.kh